## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

### សេចក្តីសំរេច លេខ ៤៦ សសរ
### ស្តីពីការ តែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រី
### នៃ ព្រះរាជាណាចក្រកម្ពុជា

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរការងារចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : តែងតាំងលោក ឡេស្រលី ឡេក ជាទីប្រឹក្សាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២ : លោក ឡេស្រលី ឡេក ត្រូវអនុវត្តនូវសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៩៩៩

### សេចក្តីសំរេច លេខ ៤៧ សសរ
### ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាព
### បញ្ហាដីធ្លី នៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា